ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សាលាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ៣៣

ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១

**សាលដីកា**

លេខ ២៦២ IV

ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១

**សាលដីកា**

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០២១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.ឯកឧត្តម [redacted] ចៅក្រមរបាយការណ៍

៣.ឯកឧត្តម [redacted] ចៅក្រម

៤.ឯកឧត្តម [redacted] ចៅក្រម

៥.លោកជំទាវ [redacted] ចៅក្រម

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៥៩៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៦៩ ក្រII -រ- ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

១.ជនជាប់ចោទឈ្មោះ [redacted] **សំបូរ** ភេទប្រុស អាយុ ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ធ្វើស្រែ មានទីកន្លែងកំណើតនៅភូមិមេន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេល[redacted] ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ [redacted] -រ- ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិលោក [redacted] ម៉ូរ៉ា



Scanned with CamScanner

២.ជនជាប់ចោទឈ្មោះ[redacted] ជ្រឹង ភេទប្រុស អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្ន[redacted] ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិត្រពាំងខ្នារ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ[redacted] -រ ម្តាយឈ្មោះ[redacted] -រ ប្រពន្ធឈ្មោះ[redacted]កូនគ្មាន ទោសពីមុនគ្មាន។

**ជាប់ចោទពីបទ** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ពានអាកាសស្ទឹងមានជ័យ... 

ក្រោយស្ថានីយប្រេងសូគីមិច ច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ែលធី សង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៦ និង២០នាទី សមត្ថកិច្ចការិយាល័យប្រឆាំងគ្រឿងញៀនខុសច្បាប់នៃមន្ទីរប្រឆាំងគ្រឿងញៀន បានអនុវត្តវិធានញុះញង់ឱ្យលក់គ្រឿងញៀនខុសច្បាប់ នៅចំណុចក្រោយស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ មានឈ្មោះ[redacted] ជ្រឹង ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ[redacted] សំបូរ ភេទប្រុស អាយុ ៣៩ឆ្នាំ ឆែកឆេរឃើញគ្រាមពណ៌សថ្លា ចំនួន ០១កញ្ចប់ (តេស្តបឋមប្រភេទមេតំហ្វេតាមីន) ទម្ងន់ ១០,១១ ក្រាម និងគ្រាមពណ៌សថ្លាមួយកញ្ចប់ទៀត (តេស្តបឋមប្រភេទមេតំហ្វេតាមីន) ទម្ងន់ ៨៧,៦១ ក្រាម ដាក់ក្នុងវ៉ាលីលើចង្កើម៉ូតូខាងមុខ។ មុនពេលកើតហេតុមានម៉ូយទំនាក់ទំនងទិញថ្នាំញៀនពីឈ្មោះ[redacted]កាស់ នៅចំណុចបន្ទប់ជួលរបស់ឈ្មោះ វាមពេលទទួលថ្នាំញៀនរួចឈ្មោះ[redacted] ជ្រឹង និងឈ្មោះ[redacted]បូរ បានយកថ្នាំញៀនទៅប្រគល់ឱ្យម៉ូយ លុះពេលពួកគេកំពុងប្រគល់ថ្នាំញៀនឱ្យម៉ូយ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តងរួចសមត្ថកិច្ចកសាងសំណុំរឿងរួមទាំងវត្ថុតាង បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦២៦-ក្រ៤-វ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោស ៖

ក.ឈ្មោះ[redacted]ជ្រឹង ភេទប្រុស អាយុ ២៣ ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងខ្នារ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន[redacted]ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ[redacted] -រ ម្តាយឈ្មោះ[redacted] -រ ប្រពន្ធឈ្មោះ[redacted]កូនគ្មាន ជាទីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ខ.ឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីកន្លែងកំណើតនៅភូមិមេន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួ[redacted]ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ [redacted] -រ- ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ជាទីតិជន ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ិលជី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.រឹបអូសវត្ថុតាងមាន ថ្នាំញៀនប្រភេទម្សៅក្រាមសថ្លាទម្ងន់ទាំងអស់សរុប៩៧,៧២ (កៅសិបប្រាំពីរក្បៀសចិតសិបពីរ) ក្រាម និងម៉ូតូម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ ១HD-៨១៨៦ លេខតួ និងលេខម៉ាស៊ីន ND125M5309112 ចំនួន ០១គ្រឿង។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជ្រើង និងឈ្មោះ [redacted] សំបូរ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ជ្រើង ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៦២៦·ក្រ៤·រ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦៧៦ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៦២៦·ក្រ៤·រ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៦៩ ក្រII·រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១/ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។



Scanned with CamScanner

២/ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ[redacted] ជ្រឹង ទុកជាត្រឹមត្រូវតាមច្បាប់។

៣/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៦៦"ក្រ"វ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ "ក" ដែលផ្តន្ទាទោសលើឈ្មោះ [redacted] ជ្រឹង ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល ត្រូវកែប្រែមក ដាក់ពន្ធនាគារកំណត់ ០៤ (បួន) ឆ្នាំ វិញ។

-ចំណុចផ្សេងពីនេះរក្សាទុកដដែល។

៤/បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៥/សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ៥៩៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] សំបូរ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១៦៩ ក្រ॥"វ" ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៦៦"ក្រ" វ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល លើកលែងតែចំនុចទី១ "ក" ដែលផ្តន្ទាទោសលើឈ្មោះ [redacted] ជ្រឹង ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល ត្រូវកែប្រែមកដាក់ពន្ធនាគារកំណត់ ០៤ (បួន) ឆ្នាំ វិញ គឺត្រឹមត្រូវហើយ។ បើផ្អែកតាមសំអាងហេតុដែលសាលាឧទ្ធរណ៍បានបង្ហាញនៅក្នុងចំណុច ៣ គឺបញ្ជាក់ថា សមត្ថកិច្ចបានឃាត់ខ្លួន និងដកហូតបានវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ម៉ាទឹកកក មានទម្ងន់សរុប ៨៧,៦១ ក្រាម ដែលមានបរិមាណជាតុសុទ្ធសរុប ៦៣,៩១ ក្រាម ពីឈ្មោះ [redacted] សំបូរ ដែលឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវផ្តន្ទាទោសកំណត់ពី ០៥ ឆ្នាំ ទៅ ១០ឆ្នាំ ដែលស្ថិតនៅក្នុងបញ្ញត្តិច្បាប់ហើយ។ ម្យ៉ាងទៀតម្ចាស់បណ្តឹងសាទុក្ខពុំបានដាក់សារណាតាមការកំណត់ឡើយ។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច



Scanned with CamScanner

១.ទទួលបណ្តឹងសាទុក្ខលេខ ៥៩៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងគតិច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៦៩ ក្រII-II ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

-លោក [redacted] ប្ញ៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សំបូរ បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងសំណុំរឿងនេះអង្គហេតុមានលក្ខណៈមិនច្បាស់លាស់ដោយ ទី១ បើនិយាយពីប្រភពនៃសារធាតុញៀនដែលបានរឹបអូស គឺពុំច្បាស់ទេ, អង្គហេតុមានពាក់ព័ន្ធទៅនឹងមនុស្ស ៤នាក់ មានឈ្មោះ [redacted] ជ្រឹង , ឈ្មោះ រាម, ឈ្មោះ [redacted] កាស់ និងឈ្មោះ [redacted] សំបូរ ដែលជាកូនក្តីខ្ញុំ។ ឈ្មោះ [redacted] ជ្រឹង បានទៅជួបឈ្មោះ ហេង ដែលឈ្មោះនេះជាអាជ្ញាធរបានប្រើវិធានញុះញង់ឱ្យលក់គ្រឿងញៀន នៅពេលដែល [redacted] ជ្រឹង ទៅជួបក៏ត្រូវបានចាប់ខ្លួនតែម្តង បន្ទាប់មកក៏ឈានទៅដល់ការចាប់ខ្លួនឈ្មោះ [redacted] សំបូរ ដែលចាំឈ្មោះ [redacted] ជ្រឹង នៅលើម៉ូតូ ហើយរកឃើញគ្រឿងញៀននៅលើម៉ូតូដែលកូនក្តីខ្ញុំបានទទួលពីឈ្មោះ រាម ផ្ញើទៅឱ្យឈ្មោះ [redacted] កាស់ ដូច្នេះ គ្រឿងញៀនមានប្រភពមកពីច្រើនកន្លែង។ ទី២ នៅលើម៉ូតូដែលកូនក្តីខ្ញុំចាំនោះរកឃើញមានកញ្ចប់គ្រឿងញៀនច្រើន ប៉ុន្តែកូនក្តីខ្ញុំបានឆ្លើយរួចហើយថា មានតែមួយកញ្ចប់ទេដែលជារបស់គាត់ នេះជាបញ្ហាមិនច្បាស់នូវបរិមាណជាតុសុទ្ធ ដែលវាជះឥទ្ធិពលទៅដល់ការដាក់ទោស ហើយជនជាប់ចោទមានគ្នា ០៤នាក់ រត់គេច ០២នាក់ ហើយ [redacted] ជ្រឹង ទទួលទោស ០២ឆ្នាំ ដោយសារមានកម្រិតនៃសារជាតុញៀនគឺ ទាបជាងកូនក្តីខ្ញុំ នេះជាបញ្ហាមួយ ពីព្រោះពួកគេបានធ្វើការជាមួយគ្នា ប៉ុន្តែស្រាប់តែមានការបែងចែកកញ្ចប់នេះជារបស់ [redacted] ជ្រឹង កញ្ចប់នោះជារបស់ [redacted] បូរទៅវិញ, សារជាតុសុទ្ធខុសគ្នា នោះ ទោសក៏ខុសគ្នាដែរ ដូចនេះ ក្នុងរឿងក្តីនេះមានការសហការណ៍គ្នាជាសហចារី។ នៅក្នុងមាត្រា ៣៥៧ និយាយអំពីសំអាងហេតុដែល ទាមទារឱ្យមានសំអាងហេតុច្បាស់លាស់ , មាត្រា ៤១៩ ប្រសិនបើសំអាងហេតុពុំច្បាស់លាស់ តុលាការកំពូលមានសិទ្ធិបដិសេធសាលដីកា។ ខ្ញុំសំណូមពរ សុំឱ្យតុលាការកំពូលមេត្តា បញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់យោបល់ របស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ។



Scanned with CamScanner

# សំអាងហេតុ

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៥៩៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោ[redacted] សំបូរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការអវត្តមានរបស់ជនជាប់ចោទ ពុំមែនជាឧបសគ្គដល់ដំណើរការជេញដោលនាពេលសវនាការពេលនេះទេ ដោយផ្អែកតាមស្មារតីមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជនជាប់ចោទពុំបានដាក់សារណាមកតុលាការកំពូលទេ តែក៏មានវត្តមានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនៅពេលនេះផងដែរ។ ដូច្នេះ តុលាការបន្តនីតិវិធីជេញដោលបានដោយពុំចាំបាច់ពន្យាពេលឡើយ។

៣-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦២៦"ក្រ២"វ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ "ក" ដែលផ្ដន្ទាទោសលើឈ្មោះ [redacted] ជ្រើង ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបីឆ្នាំ) និងពិន័យជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល ត្រូវកែប្រែមកដាក់ពន្ធនាគារកំណត់ ០៤ (បួន) ឆ្នាំ វិញ ចំណុចផ្សេងពីនេះរក្សាទុកដដែលនោះៗ ជាការត្រឹមត្រូវហើយ ព្រោះថា ជនជាប់ចោទត្រូវបានចាប់ខ្លួនក្នុងករណីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង ហើយជនជាប់ចោទនេះបានទទួលសារភាព និងបានបង្ហាញអំពីសកម្មភាពបទល្មើសដែលខ្លួនបានប្រព្រឹត្តរួចហើយដែរ។ សារធាតុញៀនដែលរឹបអូសបាននៅពេលចាប់ខ្លួន និងឆែកឆេរលើខ្លួនជនជាប់ចោទឈ្មោ[redacted]បូរ មានឈ្មោះថា មេតំហ្វេតាមីន ទម្ងន់សរុប ៨៧,៦១ ក្រាម ដែលមានបរិមាណជាតុសរុប $\frac{៨៧,៦១ ក្រាម \times ៧២,៩៥\%}{១០០}$ = ៦៣,៩១ ក្រាម, ជនជាប់ចោទឈ្មោ[redacted] ជ្រើង ដោយដកហូតបាននូវវត្ថុតាងដែលជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) មានទម្ងន់សរុប ១០,១១ ក្រាម ដែលមានបរិមាណជាតុសុទ្ធសរុប $\frac{១០,១១ ក្រាម \times ៧៥,៤៣\%}{១០០}$ = ៧,៦៣ ក្រាម ប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមានជាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំបូរ និង [redacted] ជ្រើង ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមានខ្លឹមសារក្នុងផ្នែកសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង រាជធានីភ្នំពេញ បានបញ្ជាក់ស្រាប់។

៤.យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]សំបូរ , [redacted] ជ្រើង



Scanned with CamScanner

ក្នុងការប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ពានីយប្រេងសូគិម៉ិច ច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៊ែលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ក្រុមប្រឹក្សាសូមឯកភាពទាំងស្រុង។

៥.យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ មិនមានមូលហេតុត្រឹមត្រូវស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៦.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៦៩ ក្រ II-វ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវហើយ។

**ហេតុដូច្នេះ**

**សម្រេច**

១.បដិសេធ បណ្តឹងសាទុក្ខលេខ ៥៩៧ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ១៦៩ ក្រ II-វ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ។

-ឯកឧត្តម [redacted] ជាប្រធាន

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-លោកជំទាវ [redacted] ជាចៅក្រម

-កញ្ញា [redacted] ជាក្រឡាបញ្ជី

---

**បានឃើញ**

ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner